# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

៣៣✺៤៤

## កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃច័ន្ទ ទី២៣ ខែមករាឆ្នាំ២០២៣ វេលាម៉ោង០១:០០នាទីរសៀល និងម៉ោង១៩:០០នាទីយប់នៅក្នុងរោងចក្រណាហ្គាភីស ឧបភើរសេិន លីមីតធីត អាសយដ្ឋាន ផ្លូវជាតិលេខ០១ អាគារទី២ ភូមិព្រែកគ្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំងតំណាងកម្មករនិយោជិតទាំងអស់។

**១.សមាសភាពអ្នកចូលរួម**

**ក.ភាគីតំណាងអោយក្រុមហ៊ុន**

១-លោក Cao You Gou (ប្រធានរោងចក្រ)

២-លោក ពិន ផល្លីន (ប្រធានរដ្ឋបាល)

**ខ.ភាគីតំណាងកម្មករនិយោជិត**

១-លោក សោម គឹមសាន ២-លោក សំ សាមី ៣-លោក សឿង ស៊ីនួន ៤-លោក វី តុលា ៥-លោក ភ្លីង ហួន ៦-អ្នកស្រី យ៉ុង សម្បត្តិ ៧-លោក យុង សុខមឿន ៨-អ្នកស្រី ខឿន សុខហេង ៩-លោក នូ ចុនសារ៉ន ១០-អ្នកស្រី ជា ចន្ធី ១១-អ្នកស្រី សុំអ៊ុល សូនីតា។

**២.ខ្លឹមសារអង្គប្រជុំ**

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរកាងារនៅរោងចក្រក្នុងរយ:ពេល ០២ ខែ ដោយចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ ដោយពុំសូវមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្មុគ្រចិត្តដោះស្រាយដោយផ្តល់ឲ្យភាគីនីមួយៗ មានលទ្ធភាពទទួលយកបាន និងបង្កលក្ខណ:ដោះស្រាយតាមស្ថានភាពជាក់ស្តែងដោយទាំងតំណាងរោងចក្រក៏ដូចជាតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោមៈ

១.រោងចក្របានឯកភាពផ្តល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន២៥ដុល្លារអាមេរិកក្នុង១ខែកំឡុងពេលព្យួរ ការងារ។

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ និងប្រធានក្រុមទាំងអស់ហើយនៅពេលក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃកិច្ចចរចា និងគោរពតាមនិតិវិធីច្បាប់។

**៣.លទ្ធផលអង្គប្រជុំ**

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១.រោងចក្រចាប់ផ្តើមព្យួរការងារកម្មករនិយោជិត ចំនួន៥០០នាក់។ ចាប់ផ្តើមពីថ្ងៃទី១០ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី១០ខែមេសា ឆ្នាំ២០២៣។

២.រោងចក្រផ្តល់ប្រាក់ឈ្នួល២៥ដុល្លារអាមេរិកក្នុង១ខែ បើកជូនមុនធ្វើការព្យួរការងារ។

៣.ករណីដែររោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួរនោះរោងចក្រនឹងជូនដំណឹងសល់កម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១៥:០០នាទីនាថ្ងៃដដែលនិង២០:០០យប់ថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

**៤.តាគីតំណាងសហជីព និងតំណាងកម្មករនិយោជិត**

១-លោក សោម គឹមសាន

២-លោក សំ សាមី

៣-លោក សៀង ស៊ីនួន

៤-លោក រី តុលា

៥-លោក ភ្លីង ហួន

៦-អ្នកស្រី យ៉ុង សម្បត្តិ

៧-លោក យុង សុខមឿន

៨-អ្នកស្រី ខៀន សុខហេង

៩-លោក នូ ថុនសារ៉ន

១០-អ្នកស្រី ជា ចន្ធី

១១-អ្នកស្រី ស៊ុំអ៊ុល សូនីតា

ថ្ងៃចន្ទ ២កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

ធ្វើនៅ កណ្តាល ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០២៣

**ម្ចាស់សហគ្រាស**

ព្រះរាជាណាចក្រកម្ពុជា
ណាហ្គាតីស ខបតើភ្ស
ផ្នែករដ្ឋបាល៣
ទីស្នាក់ការខេត្តកណ្តាល

Scanned with CamScanner